ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 12-Jan-2015, 10:47
CMS/CFO: Sann Rada

**នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ
ភាគីដាក់ឯកសារ: សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី
ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៥

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**
ឋាន:នៃចំណាត់ថ្នាក់ឯកសារ
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

**សេចក្តីជូនដំណឹងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទិននឹង ចម្លើយសាក្សី និងប្រតិចារឹកនានាដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២**

---

**ដាក់ដោយ:**

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖**
ពេជ អង្គ
Marie GUIRAUD

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**
ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
ម៉ុច សុវណ្ណារី

**នៅចំពោះមុខ:**

**អង្គជំនុំជម្រះសាលាដំបូង៖**
ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូរ ឧត្តរា
ចៅក្រម Claudia FENZ

**ផ្ញើជូន:**

ស៊ិន សុវ៉ន

សំ សុគង់

វ៉េន ពៅ

ទី ស្រ៊ីនណា

Emmanuel ALTIT
Olivier BAHOUGNE
Patrick BAUDOIN
Laure DESFORGES
Ferdinand DJAMMEN NZEPA
Elodie DULAC
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Michael Y. LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Mahesh RAI
Julien RIVET
Nushin SARKARATI
Beini YE

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

យ៉េត ចរិយា

William SMITH

**ជនជាប់ចោទ៖**

ខៀវ សំផន

នួន ជា

**សហមេធាវីការពារក្តី៖**

សុន អរុណ

Victor KOPPE

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN

## I. សេចក្ដីជូនដំណឹង

១. នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានដាក់បញ្ជីឯកសារដែលខ្លួនបានស្នើឡើងពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២[1]។ នៅថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឱ្យភាគីចង្អុលបង្ហាញចំពោះអង្គជំនុំជម្រះសាលាដំបូងថា តើពួកគេមានបំណងប្រើប្រាស់ចម្លើយជាលាយលក្ខណ៍អក្សរ ឬប្រតិចារឹកនានានៅក្នុងបញ្ជីឯកសារដែលខ្លួនបានស្នើឡើង ជាភស្តុតាងពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ដែរឬទេ[2]។

២. ចម្លើយជាលាយលក្ខណ៍អក្សរ និងប្រតិចារឹក មិនអាចទទួលយកបានជាភស្តុតាងដើម្បីបង្ហាញពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ លុះត្រាតែ "សាក្សីបានទទួលមរណភាព មិនអាចរកឃើញក្រោយពីបានខិតខំយកចិត្តទុកដាក់យ៉ាងសមហេតុផលរួចហើយ ឬពុំអាចរកបានដោយសារការគំរាមកំហែង ការបំភិតបំភ័យ ឬការជ្រៀតជ្រែកដោយពុំសមស្របណាមួយនោះ"[3]។

៣. បន្ទាប់ពីមានយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមិនមានបំណងប្រើប្រាស់ចម្លើយជាលាយលក្ខណ៍អក្សរ និងប្រតិចារឹកដែលមាននៅក្នុងបញ្ជីឯកសារ និងវត្ថុតាងដែលបានធ្វើបច្ចុប្បន្នភាពជាភស្តុតាងបង្ហាញពីអំពើ និងអាកប្បកិរិយារបស់ជនជាប់

---

[1] បញ្ជីឯកសារ និងវត្ថុតាងរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានធ្វើបច្ចុប្បន្នភាព ស្របតាមវិធាន ៨០ សម្រាប់សំណុំរឿង ០០២/០២ ឯកសារ **E305/14** ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤ និង សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីតាមវិធាន ៨៧(៤) សុំឱ្យទទួលយកជាភស្តុតាងនូវសក្ខីកម្មផ្ទាល់មាត់ និង ឯកសារនិងវត្ថុតាងនានាពាក់ព័ន្ធនឹងសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណីដែលភាគីបានស្នើសុំឱ្យផ្ដល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២ ឯកសារ **E307/6** ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤។

[2] ការកំណត់កាលបរិច្ឆេទសម្រាប់ការជំទាស់ទៅនឹងឯកសារផ្សេងៗទាក់ទងនឹងសំណុំរឿង ០០២/០២ ឯកសារ **E327** ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៤ កថាខណ្ឌ ៣។

[3] សេចក្ដីសម្រេចលើសេចក្ដីជំទាស់ទៅនឹងភាពអាចទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សី ជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណី និង ប្រតិចារឹកនៅក្នុងសំណុំរឿង ០០១ ដែលស្នើសុំដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ឯកសារ **E299** ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ១៧ និង សេចក្ដីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ **E96/7** ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៤ កថាខណ្ឌ ៣២ ដល់ ៣៣។

ចោទក្នុងសំណុំរឿងនេះទេ។ ទោះជាយ៉ាងណាក្តី សហមេធាវីនាំមុខកត់សម្គាល់ថា នៅក្នុងសារណានានារបស់ខ្លួនអនុលោមតាមវិធាន ៨០ ដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រាំបួននាក់ត្រូវបានស្នើសុំមកផ្តល់សក្ខីកម្ម ស្តីពីតួនាទីរបស់ជនជាប់ចោទនៅក្នុងរឿងក្តីនេះ ដោយសារភស្តុតាងរបស់ពួកគេមានសារៈសំខាន់[4] និងចម្លើយជាច្រើននៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងព័ត៌មានបន្ថែមរបស់ពួកគេដែលមាននៅក្នុងបញ្ជីឯកសារនិងវត្ថុតាងដែលបានស្នើឡើង និងមានភស្តុតាងដែលពាក់ព័ន្ធនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ[5]។ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ត្រូវបានអង្គជំនុំជម្រះសាលាដំបូងកោះហៅមកផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងត្រាំកក់[6]។ ហេតុនេះជនជាប់ចោទនឹងមានឱកាសក្នុងការតទល់ជាមួយសាក្សីរូបនេះ ជាមួយចម្លើយជាលាយលក្ខណ៍អក្សររបស់គាត់បាន។ ទោះជាយ៉ាងណាក្តី ប្រសិនបើមានដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើឡើងទាំងនេះ ដែលចម្លើយជាលាយលក្ខណ៍អក្សររបស់ខ្លួនមានភស្តុតាងពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ បានទទួលមរណភាព មិនអាចរកឃើញក្រោយពីបានខិតខំយកចិត្តទុកដាក់យ៉ាងសមហេតុផលរួចហើយ ឬពុំអាចរកបានដោយសារការគំរាមកំហែង ការបំភិតបំភ័យ ឬការជ្រៀតជ្រែកដោយពុំសមស្របណាមួយ[7] ហើយហេតុ

---

[4] បញ្ជីឯកសារ និងវត្ថុតាងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានធ្វើបច្ចុប្បន្នភាព ស្របតាមវិធាន ៨០ សម្រាប់សំណុំរឿង ០០២/០២ ជាមួយឧសម្ព័ន្ធសម្ងាត់ ឧបសម្ព័ន្ធ ៤៖ សំណើសុំស្តីពីលំដាប់លំដោយនៃការជំនុំជម្រះរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ **E305/7.1.4** ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៤ ឧបសម្ព័ន្ធ ៤៖ សំណើសុំស្តីពីលំដាប់លំដោយនៃការជំនុំជម្រះរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ឧទាហរណ៍ និង ដោយមានរហស្សនាមដែលបានធ្វើបច្ចុប្បន្នភាព 2-TCCP-250, 2-TCCP-253, 2-TCCP-258, 2-TCCP-268, 2-TCCP-237, 2-TCCP-219, 2-TCCP-235, 2-TCCP-286)។

[5] បញ្ជីឯកសារ និងវត្ថុតាងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានធ្វើបច្ចុប្បន្នភាព ស្របតាមវិធាន ៨០ សម្រាប់សំណុំរឿង ០០២/០២ ឧបសម្ព័ន្ធ ៥៖ បញ្ជីឯកសារ និងវត្ថុតាងដែលបានធ្វើបច្ចុប្បន្នភាព ឯកសារ **E305/14.1** ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤។ សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីតាមវិធាន ៨៧(៤) សុំឱ្យទទួលយកជាភស្តុតាងនូវសក្ខីកម្មផ្ទាល់មាត់ និង ឯកសារនិងវត្ថុតាងនានាពាក់ព័ន្ធនឹងសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលភាគីបានស្នើសុំឱ្យផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២ ឯកសារ **E307/6** ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤។

[6] 2-TCCP-238 (ឯកសារ E3/5635 ឯកសារ E9/32.2.28)។

[7] *សូមមើល* សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ **E96/7** ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៤ កថាខណ្ឌ ៣២ ដល់ ៣៣ និង សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងភាពអាចទទួលយកកំណត់ហេតុស្តាប់ចម្លើយ

នេះមិនអាចមកផ្តល់សក្ខីកម្មបាននោះ សហមេធាវីនាំមុខសូមរក្សាសិទ្ធិដាក់ចម្លើយជាលាយលក្ខណ៍អក្សររបស់អ្នកទាំងនោះជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ។

សូមលោក លោកស្រីចៅក្រមមេត្តាទទួលយកសេចក្តីជូនដំណឹងនេះដោយគោរព។

| **កាលបរិច្ឆេទ** | **នាម** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៥ | **ពេជ អង្គ**<br>សហមេធាវីនាំមុខជាតិ | ភ្នំពេញ | |
| | **Marie GUIRAUD**<br>សហមេធាវីនាំមុខអន្តរជាតិ | ភ្នំពេញ | |